# នីតិអន្តរជាតិសាធារណៈ
# PUBLIC INTERNATIONAL LAW

## មេរៀនទី ១៦

LECTURE 16

## ដំណោះស្រាយវិវាទអន្តរជាតិ

INTERNATIONAL DISPUTE RESOLUTION

# មាតិកា

- កម្មវត្ថុនៃមេរៀន
- ផ្នែកទី១ សេចក្តីផ្តើម
- ផ្នែកទី២ ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ
    - សញ្ញាណទូទៅ
    - ការដោះស្រាយវិវាទអន្តររដ្ឋ
    - ការដោះស្រាយវិវាទដោយអង្គការអន្តរជាតិ
- ផ្នែកទី៣ ដំណោះស្រាយវិវាទតាមផ្លូវតុលាការ
    - សញ្ញាណទូទៅ
    - ការរៀបចំតុលាការ
    - សមត្ថកិច្ចតុលាការ

# កម្មវត្ថុនៃមេរៀន

នៅក្នុងមេរៀនស្តីពីដំណោះស្រាយវិវាទអន្តរជាតិ មានគោលបំណងឲ្យអ្នកសិក្សាបានស្វែងយល់ពី៖

- អ្វីទៅជាជម្លោះអន្តរជាតិ និងវិវាទអន្តររដ្ឋ
- ការដោះស្រាយវិវាទក្របខ័ណ្ឌអង្គការអន្តរជាតិ
- គុណសម្បត្តិ និងគុណវិបត្តិនៃការដោះស្រាយវិវាទ
- វិធីសាស្ត្រនានាប្រើប្រាស់សម្រាប់ការដោះស្រាយវិវាទ
- ការដោះស្រាយវិវាទតាមផ្លូវតុលាការ និងក្រៅផ្លូវតុលាការ

# ផ្នែកទី១ សេចក្តីផ្តើម

មេរៀនស្តីពីដំណោះស្រាយវិវាទអន្តរជាតិនេះ យើងនឹងសិក្សាទៅលើតែ ពីការដោះស្រាយវិវាទដោយសន្តិវិធី យើងនឹងពុំសិក្សា ពីការដោះស្រាយវិវាទដោយមធ្យោបាយនៃការប្រើប្រាស់កម្លាំងឡើយ។ ការបង្កើតទំនាក់ទំនងការទូត និងកុងស៊ុល ជាសញ្ញានៃការដោះស្រាយវិវាទដោយសន្តិវិធី។

# ផ្នែកទី១ សេចក្ដីផ្ដើម

ដូចដែលបានបញ្ញត្តិ ដោយធម្មនុញ្ញអង្គការសហប្រជាជាតិ ការហាមប្រើប្រាស់កម្លាំង គឺជាកាតព្វកិច្ចរបស់រដ្ឋ ក្នុងការដោះស្រាយវិវាទ។ តែទោះបីនេះវាគឺជាកាតព្វកិច្ចយ៉ាងណាក៏ដោយ ក៏រដ្ឋនីមួយៗនៅតែមានជម្រើសក្នុងការប្រើប្រាស់នូវវិធីសាស្ត្រផ្សេងៗ ដើម្បីជាមធ្យោបាយដោះស្រាយវិវាទ។

# ផ្នែកទី១ សេចក្ដីផ្ដើម

រឿងក្ដីPCIJ ស្ដីពីកិច្ចសន្យាសម្បទានម៉ាវរ៉ូម៉ាទីស នៅប៉ាឡេស្ទីន ឆ្នាំ១៩២៤ ពាក្យថាវិវាទ មានន័យថា ជាការមិនត្រូវរូវគ្នាផ្នែកណាមួយនៃអង្គច្បាប់ ឬ អង្គហេតុ ដែលនាំឲ្យមានអធិករណ៍។ បើតាមវចនានុក្រមសម្ដេចសង្ឃរាជ ជួន ណាត គឺជាដំណើរទាស់ទែងគ្នា ដំណើរឈ្លោះប្រកែកគ្នា ជាអាទិ៍។

# ផ្នែកទី១ សេចក្ដីផ្ដើម

ឆន្ទៈដែលជំរុញឲ្យរដ្ឋដែលមានអធិករណ៍និងគ្នា ធ្វើការដោះស្រាយវិវាទរបស់ខ្លួនដោយសន្តិភាពវិធី ត្រូវបានចង់ក្រងឲ្យទៅជាបទដ្ឋានដែល៏្បមានលក្ខណៈជាលាយ័លក្ខអក្សរ ដែលមានឈ្មោះថា អនុសញ្ញាទីក្រុងឡាអេ នាថ្ងៃទី១៨ ខែតុលា ឆ្នាំ១៩០៧។

# ផ្នែកទី១ សេចក្តីផ្តើម

ដូចដែលបានលើកឡើងពីខាងដើម កាតព្វកិច្ចក្នុងការដោះស្រាយវិវាទដោយសន្តិវិធី ត្រូវបានចែងនៅក្នុងធម្មនុញ្ញរបស់អង្គការសហប្រជាមាត្រា២.៣ និង៣៣។ វាក៏មានក្នុងសេចក្តីថ្លែងការទាក់ទងនិង គោលការណ៍អន្តរជាតិស្តីពីទំនាក់ទំនងអន្តរជាតិ និងសហប្រត្តិបត្តការរវាងរដ្ឋ និងរដ្ឋ។

# ផ្នែកទី១ សេចក្ដីផ្ដើម

រដ្ឋនីមួយៗ មានសិទ្ធិពេញលេញ ក្នុងការជ្រើសរើសនូវវិធីក្នុងការដោះស្រាយវិវាទរបស់ខ្លួន ដោយអាចជ្រើសរើសការដោះស្រាយតាមផ្លូវតុលាការ ឬក៏អាចជ្រើសរើសការដោះស្រាយក្រៅផ្លូវតុលាការ ដូចដែលបានបញ្ញត្តិក្នុងធម្មនុញ្ញរបស់អង្គការសហប្រជាតិមាត្រា៣៣។

# ផ្នែកទី១ សេចក្តីផ្តើម

រដ្ឋអាច អាចធ្វើការចែងទុកជាមុននូវវិធីសាស្ត្រ ដែលយកមកប្រើសម្រាប់ធ្វើការដោះស្រាយវិវាទ នៅក្នុងសន្ធិសញ្ញា ឬក៏កិច្ចព្រមព្រៀង។ ហើយនៅពេលកើតមានវិវាទ ពួកគេអាចប្រើប្រាស់នូវវិធីដែលបានព្រមព្រៀងរួចហើយ ក្នុងការដោះស្រាយវិវាទបាន។

# ផ្នែកទី២ ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

- សញ្ញាណទូទៅ

ការដោះស្រាយវិវាទនេះ អាចធ្វើឡើងក្នុងក្របខ័ណ្ឌរដ្ឋ និងរដ្ឋ ឬ អាចធ្វើឡើងក្នុងក្របខ័ណ្ឌអង្គការអន្តរជាតិណាមួយក៏បាន ដូចជាអាចត្រូវធ្វើឡើងក្នុងក្របខ័ណ្ឌរបស់អង្គការសហប្រជាជាតិ ជាអាទ៍។

# ផ្នែកទី២ ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

- សញ្ញាណទូទៅ

ការដោះស្រាយវិវាទ ក្រៅប្រព័ន្ធតុលាការ អាចត្រូវបានធ្វើឡើងតាមមធ្យោបាយជាច្រើនដូចជា ការដោះស្រាយដោយការចរចារ ការផ្សះផ្សា ការធ្វើសន្ធានកម្ម និងការដោះស្រាយដោយការធ្វើមជ្ឈត្តកម្ម។

# ផ្នែកទី២ ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

- ការដោះស្រាយវិវាទអន្តររដ្ឋ

នៅពេលមានវិវាទកើតឡើង រដ្ឋអាចធ្វើការដោះស្រាយនូវបញ្ហាដែលបានកើតឡើង តាមរយៈការចរចារដោយខ្លួនឯក ឬ អាចមានការជួយជ្រោមជ្រែងពីរដ្ឋតតិយភាគី ឲ្យភាគីចូលទៅកាន់តុចរចារ ដើម្បីបញ្ចប់អធិករណ៍នោះ។

# ផ្នែកទី២ ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

- ការដោះស្រាយវិវាទអន្តររដ្ឋ

ការចរចារ: ជាវិធីសាស្ត្រមួយសម្រាប់ដោះស្រាយវិវាទ ដែលមានលក្ខណៈងាយស្រួល។ រដ្ឋភាគីអាចជួបគ្នា ដើម្បីធ្វើការដោះស្រាយវិវាទដោយស្មោះត្រង់ ហើយគេតែងសង្កេតឃើញការចរចារអាចកើតមានឡើងស្ទើតែរាល់ថ្ងៃនៃជីវិតរស់នៅប្រចាំថ្ងៃរបស់មនុស្ស។

# ផ្នែកទី២ ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

- ការដោះស្រាយវិវាទអន្តររដ្ឋ

ការចរចារ: ជានីតិវិធីដំបូងជាចាំបាច់មុនពេលចាប់ផ្តើមវិធីសាស្រ្តស្មុកស្មាញផ្សេងទៀត ដូចជាការដោះស្រាយតាមសន្ធានកម្ម ឬ មជ្ឈត្តកម្ម ជាអាទិ៍។ ពេលខ្លះ ការចរចារជានីតិវិធីបន្ថែមសម្រាប់បញ្ចប់នីតិវិធីតាមផ្លូវតុលាការ។

# ផ្នែកទី២ ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

- ការដោះស្រាយវិវាទអន្តររដ្ឋ

<u>ការចរចា</u>: វិធីនេះអាចប្រែប្រួល ជួនកាលវាជាការចរចារទ្វេភាគី ហើយពេលខ្លះវាអាចជាការចរចារពហុភាគី ទន្ទឹមនិងនេះ ពេលខ្លះការចរចារទទួលបានលទ្ធផលល្អ និងជួនកាលទទួលបានលទ្ធផលមិនល្អ។

# ផ្នែកទី២ ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

- ការដោះស្រាយវិវាទអន្តររដ្ឋ

<u>ការចរចា</u>៖ ឥស្សរភាពរបស់អ្នកចរចាអាចមានដូជា នាយករដ្ឋមន្រ្តី ប្រធានាធិបតី ឥស្សរជនជាន់ខ្ពស់ដែលមានភាពល្បីល្បាញ និងស្របទៅតាមជំនាញ។ ជាទូទៅការចរចារដោយផ្ទាល់រវាងភាគី និងភាគីពុំសូវទទួលបានផលល្អទេ ជាហេតុធ្វើឲ្យតែងស្វែងរកភាគីទីបីឲ្យចូលរួម។

# ផ្នែកទី២ ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

- ការដោះស្រាយវិវាទអន្តររដ្ឋ

<u>ការចរចា</u>: ការដោះស្រាយវិវាទតាមការចរចារ អាចផ្តល់នូវគុណសម្បត្តិ និងគុណវិប្បត្តិ។ ចំពោះគុណសម្បត្តិ គឺធ្វើឲ្យភាគីចំណេញពេលវេលា និងថវិការ អាចរក្សាបាននូវភាពស្និតស្នាលរវាងគូភាគី និងចំណងទាក់ទងល្អ ជាអាទ៍។

# ផ្នែកទី២ ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

- ការដោះស្រាយវិវាទអន្តររដ្ឋ

ការចរចារ: ចំពោះគុណវិប្បត្តិវិញ គឺអាធ្វើឲ្យភាគីបាត់បង់នៅតុល្យភាព អាចដោយសារភាគីម្ខាងទៀតមានអំណាចជាង និងជួនកាលត្រូវចំណាយពេលឥតប្រយោជន៍ ព្រោះតែភាគីម្ខាងទៀតពុំមានឆន្ទៈពិតប្រាកដក្នុងការចរចារ។

# ផ្នែកទី២ ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

- ការដោះស្រាយវិវាទអន្តររដ្ឋ

ការផ្សះផ្សា: វិធីនៃការដោះស្រាយនេះ អ្នកផ្សះផ្សាអាចចាប់ផ្តើមការងាររបស់ខ្លួនដោយការអង្កេតពីហេតុការណ៍ ដែលបានកើតឡើងជាមុនសិន និងដោយផ្អែកទៅលើមូលដ្ឋាននៃហេតុការណ៍ អ្នកផ្សះផ្សាអាចស្នើឲ្យមានការព្រមព្រៀង។

# ផ្នែកទី២ ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

- ការដោះស្រាយវិវាទអន្តររដ្ឋ

ការផ្សះផ្សា: អ្នកផ្សះផ្សា ត្រូវយកហេតុការណ៍ដែលបានកើតឡើងមកធ្វើការពិនិត្យ និងធ្វើការសិក្សាឲ្យបានគ្រប់ជ្រុងជ្រោយ ដើម្បីទាញចេញនូវដំណោះស្រាយ ហើយដំណោះស្រាយដែលស្នើមកនេះ ពុំមានលក្ខណៈចាប់បង្ខំទេ។

# ផ្នែកទី២ ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

- ការដោះស្រាយវិវាទអន្តររដ្ឋ

ការផ្សះផ្សា: មិនខុសពីការចរចារទេ ការផ្សះផ្សាក៏បានផ្តល់នូវគុណសម្បត្តិ និងគុណវិប្បត្តផងដែរ។ អ្វីដែលសំខាន់ជាងគេ គឺភាគីនៃវិវាទ ថាតើពួកគេពិតជាមានឆន្ទៈនូវក្នុងការចូលរួមដោះស្រាវវិវាទនោះដែរឬទេ។

# ផ្នែកទី២ ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

- ការដោះស្រាយវិវាទអន្តររដ្ឋ

សន្ធានកម្ម: វាគឺជាវិធីសាស្រ្តមួយទៀត ក្នុងការដោះស្រាយវិវាទ ដែលភាគីអាចរកភាគីទីបីក្នុងការចូលខ្លួនមកជួយស្វែងរកនូវដំណោះស្រាយ ហើយភាគីទីបីនេះគេហៅថាជាសន្ធានករី។

# ផ្នែកទី២ ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

- ការដោះស្រាយវិវាទអន្តររដ្ឋ

<u>សន្ធានកម្ម</u>: ភាគីអាចព្រមព្រៀងគ្នា ដើម្បីធ្វើការជ្រើសរើសសន្ធានការី។ សន្ធានការី ធ្វើការសិក្សាផ្ទៀងផ្ទាត់អធិករណ៍ដែលបានកើតឡើង និងគោលជំហររបស់ភាគីនៃវិវាទទាំងសងខាង ហើយធ្វើការស្នើឡើងនូវជម្រើសជូនគូភាគី។

# ផ្នែកទី២ ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

- ការដោះស្រាយវិវាទអន្តររដ្ឋ

សន្ទានកម្ម: សំណើដែលស្នើឡើងដោយសន្ទានការី ពុំមានលក្ខណៈចាប់បង្ខំទេ។ ប្រសិនបើគូភាគីមានការយល់ព្រមទៅនិងសំណើដែលលើកឡើង ពួកគាត់អាចធ្វើកិច្ចព្រមព្រៀង ហើយអាចយកការព្រមព្រៀងនេះទៅអនុវត្តបាន។

# ផ្នែកទី២ ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

- ការដោះស្រាយវិវាទអន្តររដ្ឋ

សន្ធានកម្ម: ពុំមានអ្វីខុសពីវិធីសាស្ត្រទាំងពីរខាងលើទេ ការធ្វើសន្ធានកម្មក៏ផ្តល់នូវគុណសម្បត្តិ និងគុណវិប្បត្តដូចគ្នាក្នុងករណីសន្ធានកម្ម ប្រសិនបើសន្ធានការីដែលត្រូវបានជ្រើសរើសនោះ មិនមានឯករាជ្យធ្វើឲ្យភាគីបាត់បង់ផលប្រយោជន៍ទៅវិញ។

# ផ្នែកទី២ ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

• ការដោះស្រាយវិវាទអន្តររដ្ឋ

មជ្ឈត្តកម្ម: គឺជាមធ្យោបាយមួយទៀតក្នុងការដោះស្រាយវិវាទ។ វិធីនេះមានលក្ខណៈស្រដៀងទៅនឹងការដោះស្រាយវិវាទតាមផ្លូវតុលាការដែរ ប៉ុន្តែការដោះស្រាយដោយវិធីនេះគូភាគីមានសិទ្ធិក្នុងការធ្វើការជ្រើសរើសនូវមជ្ឈត្តករ។

# ផ្នែកទី២ ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

- ការដោះស្រាយវិវាទអន្តររដ្ឋ

មជ្ឈត្តកម្ម: ភាគីអាចធ្វើការជ្រើសរើសនូវមជ្ឈត្តករ ដែលខ្លួនពេញចិត្ត ហើយមជ្ឈត្តករដែលភាគីបានជ្រើសរើស ត្រូវធ្វើការជ្រើសរើសមជ្ឈត្តករឯករាជ្យមួយរូបធ្វើជាប្រធាន។ ភាគីអាចព្រមព្រៀងលើចំនួននៃមជ្ឈត្តករ តែមិនត្រូវមានចំនួនគូទេ។

# ផ្នែកទី២ ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

- ការដោះស្រាយវិវាទអន្តររដ្ឋ

មជ្ឈត្តកម្ម: ភាគីមិនត្រឹមតែអាចជ្រើសរើសមជ្ឈត្តករទេ ពួកគេក៏អាចធ្វើការជ្រើសរើសទម្រង់នៃមជ្ឈត្តិវិនិច្ឆ័យ ផងដែរ។ ពួកគេអាចជ្រើសរើសយកមជ្ឈត្តវិនិច្ឆ័យដែលជាប់កាតព្វកិច្ច ឬ ក៏មជ្ឈត្តវិនិច្ឆ័យដែលមិនជាប់កាតព្វកិច្ច។

# ផ្នែកទី២ ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

- ការដោះស្រាយវិវាទអន្តររដ្ឋ

មជ្ឈត្តកម្ម: មិនខុសអ្វីពីវិធីសាស្ត្រទាំងឡាយដែលបានលើកឡើងពីខាងលើទេ មជ្ឈត្តកម្មផ្តល់នូវគុណសម្បត្តិ និងផ្តល់នូវគុណវិប្បត្តដូចគ្នា។ ហើយក៏ដូចដែលបានលើកឡើងខាងលើដែល កត្តាសំខាន់ជាងគេគឺវាអាស្រ័យលើឆន្ទៈភាគី។

# ផ្នែកទី២ ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

- ការដោះស្រាយវិវាទដោយអង្គការអន្តរជាតិ

អង្គការអន្តរ អាចដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយដោះស្រាយនូវវិវាទនានារវាងរដ្ឋ និងរដ្ឋ។ អង្គការអន្តរជាតិទាំងនោះ អាចជាអង្គការដែលលក្ខណៈជាសាកល ឬ ជាអង្គការដែលមានសមត្ថភាពទៅតាមជំនាញផ្សេងៗគ្នា។

# ផ្នែកទី២ ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

- ការដោះស្រាយវិវាទដោយអង្គការអន្តរជាតិ

អង្គការដែលមានលក្ខណៈជាសាកល គឺអាចជាសង្គមប្រជាជាតិ និងបច្ចុប្បន្នគឺអង្គការសហប្រជាជាតិ។ ការដោះស្រាយដែលធ្វើឡើងដោយអង្គការនេះគឺ ត្រូវធ្វើឡើងដោយក្រុមប្រឹក្សាសន្តិសុខ។

# ផ្នែកទី២ ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

- ការដោះស្រាយវិវាទដោយអង្គការអន្តរជាតិ

ក្រៅពីក្រុមប្រឹក្សាសន្តិសុខ មហាសន្និបាតអង្គការសហប្រជាជាតិ និងអគ្គលេខាធិការនៃអង្គការនេះក៏អាចចូលរួមក្នុងការស្វែងរកដំណោះស្រាយនៃវិវាទដែលបានកើតឡើង គ្រាន់តែគ្មានអំណាចសម្រេចដាច់ខាតទេ។

# ផ្នែកទី២ ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

- ការដោះស្រាយវិវាទដោយអង្គការអន្តរជាតិ

មាត្រា២៤ ធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ បានបញ្ញត្តិថា ក្រុមប្រឹក្សាសន្តិសុខមានការទទួលខុសត្រូវជាចម្បងក្នុងការថែរក្សាសន្តិភាព និងសន្តិសុខអន្តរជាតិ។ ក្រៅពីនេះ នៅមានអង្គការជំនាញផ្សេងៗទៀត ដូចជា អង្គការពាណិជ្ជកម្មពិភពលោក អង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ ជាអាទិ៍។

# ផ្នែកទី៣ ដំណោះស្រាយវិវាទតាមផ្លូវតុលាការ

- សញ្ញាណទូទៅ

ដំណោះស្រាយវិវាទតាមវិធីនេះ គឺនាំឲ្យមានការអន្តរាគមន៍ពីស្ថាប័នឯករាជ្យ ក្នុងការចេញនូវសេចក្តីសម្រេចដែលមានលក្ខណៈចាប់បង្ខំឲ្យគូភាគីត្រូវតែអនុវត្ត ឧទាហរណ៍ ករណីរឿងក្តីប្រាសាទព្រះវិហាររវាងប្រទេសកម្ពុជា និងថៃ។

# ផ្នែកទី៣ ដំណោះស្រាយវិវាទតាមផ្លូវតុលាការ

- សញ្ញាណទូទៅ

សូមធ្វើការកត់សម្គាល់ថា ឈរលើគោលការណ៍នៃការគោរពអធិបតេយ្យរដ្ឋ រដ្ឋជាប់ពាក់ព័ន្ធអាចធ្វើការបដិសេធមិនទទួលយកនូវសមត្ថកិច្ចរបស់តុលាការបាន។ យ៉ាងនេះហើយទើបនាំឲ្យការទទួលយកនូវសមត្ថកិច្ចរបស់តុលាការជាមុន ឬ ជាក្រោយ។

# ផ្នែកទី៣ ដំណោះស្រាយវិវាទតាមផ្លូវតុលាការ

- សញ្ញាណទូទៅ

ការដោះស្រាយវិវាទតាមផ្លូវតុលាការ នៅក្នុងមេរៀននេះ យើងនឹងលើកចំណុចគោលៗ មួយចំនួនរបស់តុលាការយុត្តិធម៌អន្តរជាតិ មកធ្វើការសិក្សាតែប៉ុណ្ណោះ ចំពោះស្ថាប័នតុលាការផ្សេងៗ ទៀតយើងមិនលើកយកមកសិក្សាទេ។

# ផ្នែកទី៣ ដំណោះស្រាយវិវាទតាមផ្លូវតុលាការ

- ការរៀបចំតុលាការ

តុលាការយុត្តិធម៌អន្តរជាតិ មានសមាសភាពចៅក្រមចំនួន ១៥រូប ហើយដែលត្រូវជ្រើសរើសចេញពីរដ្ឋដែលជាសមាជិករបស់តុលាការនេះ ដោយឈរលើគោលការណ៍នៃការបែងចែកចំនួនទៅតាមភូមិសាស្ត្រ។

# ផ្នែកទី៣ ដំណោះស្រាយវិវាទតាមផ្លូវតុលាការ

- ការរៀបចំតុលាការ

ជាគោលការណ៍ ពុំមានចៅក្រមលើសពីមួយរូប ដែលត្រូវជ្រើសរើសចេញពីប្រទេសតែមួយនោះឡើយ។ ចៅក្រមត្រូវមានឯករាជ្យភាព ពីប្រទេសរបស់ខ្លួន គឺគាត់មិនបំពេញមុខងារតំណាងឲ្យរដ្ឋខ្លួន ក្នុងអាណត្តិនៃតុលាការនេះ។

# ផ្នែកទី៣ ដំណោះស្រាយវិវាទតាមផ្លូវតុលាការ

- ការរៀបចំតុលាការ

ចៅក្រមនៃតុលាការយុត្តិធម៌អន្តរជាតិ មានអាណត្តិ៩ឆ្នាំ ហើយចៅក្រមចំនួនមួយភាគបី ត្រូវរៀបចំធ្វើការបោះឆ្នោតឡើងវិញជារាងរាល់រយៈពេល៣ឆ្នាំម្តង។ ចៅក្រមត្រូវមានលក្ខណៈសម្បត្តិដូចជា មានភាពចាស់ទុំផ្នែកច្បាប់អន្តរជាតិ មិនធ្លាប់មានទោស និងមានប្រវត្តិវិជ្ជាជីវៈល្អ ជាអាទ៍។

# ផ្នែកទី៣ ដំណោះស្រាយវិវាទតាមផ្លូវតុលាការ

- ការរៀបចំតុលាការ

តុលាការនេះ អាចដំណើការសវនាការទៅបានលុះណាមាន កូរ៉ុមចៅក្រមចំនួន៩រូប។ នៅក្នុងនីតិវិធីរបស់តុលាការអាច មានចៅក្រមរហូតដល់ទៅចំនួន១៥រូប។ តុលាការនេះ មាន ទីតាំងស្ថិតនៅទីក្រុងឡាអេប្រទេសហូឡង់។

# ផ្នែកទី៣ ដំណោះស្រាយវិវាទតាមផ្លូវតុលាការ

- សមត្ថកិច្ចតុលាការ

តុលាការនេះ មានសមត្ថកិច្ចតែចំពោះរដ្ឋដែលជាសមាជិករបស់ខ្លួនតែប៉ុណ្ណោះ។ តុលាការនេះដើរតួជាអ្នកធ្វើសេចក្តីវិនិច្ឆ័យទៅលើរឿងក្តី និងក៏ដើរតួនាទីជាអ្នកផ្តល់នូវយោបល់ពិគ្រោះផងដែរ។

# ផ្នែកទី៣ ដំណោះស្រាយវិវាទតាមផ្លូវតុលាការ

- សមត្ថកិច្ចតុលាការ

សមត្ថកិច្ចរបស់តុលាការនេះ រដ្ឋអាចទទួលយកតាមបីរបៀប មានដូចជា សមត្ថកិច្ចព្រមព្រៀងសម្របសម្រួល កិច្ចព្រមព្រៀងស្តីពីយុត្តាធិការបង្ខំ និងការទទួលយល់ព្រមខមិនបង្ខំនៃយុត្តាធិការបង្ខំ។

# ផ្នែកទី៣ ដំណោះស្រាយវិវាទតាមផ្លូវតុលាការ

ការដោះស្រាយវិវាទតាមផ្លូវតុលាការ ជាពិសេសតុលាការយុត្តិធម៌អន្តរជាតិ ពិតជាអាចស្វែងរកយុត្តិធម៌ជូនគូភាគី។ ប៉ុន្តែ វាក៏ត្រូវប្រើនូវពេលវេលាយូរ និងចំណាយនូវថវិការជាតិយ៉ាងច្រើនសន្ធឹកសន្ធាប់ផងដែរ។ តែទោះជាយ៉ាងណាវានូវតែជាជម្រើសដ៏ល្អមួយ សម្រាប់ធ្វើការបញ្ចប់វិវាទ។

មេរៀនទី១៦ ស្តីពីដំណោះស្រាយវិវាទអន្តរជាតិ ត្រូវបានបញ្ចប់។ សូមអរគុណ សម្រាប់ការតាមដានដោយយកចិត្តទុកដាក់ពីសំណាក់អ្នកសិក្សាទាំងឡាយ។